Maine Center for Disease Control and Prevention
An Office of the Department of Health and Human Services

**<u>សំណួរសួរញឹកញាប់--ទំព័រទី 19</u>**

## ប្រសិនបើខ្ញុំមានសិទ្ធិទទួលបាន WIC តើខ្ញុំអាចទទួលបានអត្ថប្រយោជន៍រយៈពេលយូរប៉ុណ្ណា?

- ក្នុងពេលមានផ្ទៃពោះ
- រហូតដល់មួយឆ្នាំ បន្ទាប់ពីសម្រាលកូន ប្រសិនបើអ្នកបំបៅដោះកូនរបស់អ្នកដោយទឹកដោះម្ដាយ
- រហូតដល់ប្រាំមួយខែ បន្ទាប់ពីសម្រាលកូន ប្រសិនបើអ្នកមិនបំបៅកូនដោយទឹកដោះម្ដាយ
- រហូតដល់ថ្ងៃខួបកំណើតលើកទីប្រាំរបស់កូន

## ចុះប្រសិនបើខ្ញុំផ្លាស់ទីលំនៅ?

ប្រសិនបើអ្នកមានគម្រោងផ្លាស់ទីលំនៅទៅកន្លែងផ្សេងនៅក្នុងរដ្ឋ Maine អ្នកអាចបើកមើលគេហទំព័ររបស់យើងសម្រាប់បញ្ជីឈ្មោះការិយាល័យ WIC ទាំងអស់នៅក្នុងរដ្ឋនេះតាមអាសយដ្ឋាន **www.wicforme.com**។ ប្រសិនបើអ្នកមានគម្រោងផ្លាស់ទីលំនៅចេញពីរដ្ឋ Maine សូមជូនដំណឹងឲ្យបុគ្គលិក WIC បានដឹងផង។

## តើអ្វីទៅជាតំណាងពេញសិទ្ធិ?

តំណាងពេញសិទ្ធិ គឺជាមនុស្សដែលអ្នកទុកចិត្ត។ អ្នកផ្ដល់ការអនុញ្ញាតឱ្យបុគ្គលនេះប្រើសែក WIC របស់អ្នកនៅហាងលក់គ្រឿងទេស ឬដើម្បីចូលរួមការណាត់ជួប WIC ជួសរូបអ្នក។ ប្រសិនបើអ្នកចាត់តាំងនរណាម្នាក់ឱ្យធ្វើជាតំណាងពេញសិទ្ធិ បុគ្គលនោះត្រូវតែ៖

- ចុះហត្ថលេខានៅផ្នែកខាងក្រោយនៃសីមី WIC
- យកវាទៅហាង នៅពេលប្រើសែក WIC
- យល់ដឹងថា អាហារអ្វីខ្លះដែលត្រូវទិញ និងវិធីប្រើសែក WIC
- យកសីមីនេះទៅជាមួយក្នុងពេលណាត់ជួប WIC រួមជាមួយនឹងទម្រង់បែបបទកំណត់អត្តសញ្ញាណ

## ហេតុអ្វីបានជាបុគ្គលិក WIC មិនអាចពិគ្រោះជាមួយសមាជិកគ្រួសារផ្សេងទៀត ឬមិត្តភ័ក្តិរបស់ខ្ញុំអំពីកូនរបស់ខ្ញុំ ឬរូបខ្ញុំផ្ទាល់?

កម្មវិធី WIC ការពារសិទ្ធិឯកជនរបស់អ្នក។ WIC នឹងមិនចែករំលែកព័ត៌មានណាមួយដោយគ្មានការអនុញ្ញាតរបស់អ្នកឡើយ។ នេះរួមបញ្ចូលទាំងពេលវេលាណាត់ជួប និងព័ត៌មានវេជ្ជសាស្ត្រ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើសមាជិកបុគ្គលិក WIC ជឿជាក់ថា កុមារម្នាក់កំពុងមានគ្រោះថ្នាក់ ច្បាប់តម្រូវឲ្យបុគ្គលិកនោះរាយការណ៍ពីករណីនេះទៅកាន់សមាជិកបុគ្គលិក DHHS ដែលនឹងតាមដានជាមួយគ្រួសាររបស់កុមារនោះ។

Maine Center for Disease Control and Prevention
An Office of the Department of Health and Human Services

**ចុះប្រសិនបើសែក WIC របស់ខ្ញុំបានបាត់ ត្រូវចោរលួច ឬខូច?**

សូមជូនដំណឹងដល់ការិយាល័យ WIC របស់អ្នកភ្លាមៗ។ សូមចាត់ទុកសែក WIC របស់អ្នកដូចជាសាច់ប្រាក់។ ទុកសែកទាំងនោះនៅកន្លែងដែលមានសុវត្ថិភាព។

**តើខ្ញុំត្រូវទិញអ្វីៗទាំងអស់ដែលមាននៅលើសែក WIC របស់ខ្ញុំឬ?**

ទេ អ្នកមិនត្រូវបានតម្រូវឱ្យទិញអ្វីៗទាំងអស់ដែលមាននៅលើសែក WIC របស់អ្នកនោះទេ។ សូមទិញអាហារដែលអ្នកដឹងថានឹងប្រើ។

**ចុះបើខ្ញុំបានចាយសែក WIC របស់ខ្ញុំទាំងអស់ ហើយអស់ម្សៅទឹកដោះសម្រាប់កូនរបស់ខ្ញុំ?**

WIC អាចត្រឹមតែផ្តល់ម្សៅទឹកគោះចំនួនជាក់លាក់មួយជូននៅខែនីមួយៗ។ នៅពេលកូនរបស់អ្នកកាន់តែធំ វាអាចត្រូវការម្សៅទឹកដោះគោកាន់តែច្រើនជាងចំនួនម្សៅទឹកដោះគោដែលអ្នកទទួលបានពី WIC ។ ប្រសិនបើករណីនេះកើតឡើង អ្នកនឹងត្រូវទិញម្សៅទឹកដោះគោបន្ថែម រហូតដល់ពេលចាប់ផ្តើមទទួលសែក WIC បន្ទាប់របស់អ្នក។

**តើខ្ញុំអាចចូលរួមក្នុងកម្មវិធី WIC ច្រើនជាងមួយក្នុងពេលតែមួយបានទេ?**

ទេ។

**ហេតុអ្វីបានជាបុគ្គលិក WIC មិនអាចពិគ្រោះជាមួយសមាជិកគ្រួសារផ្សេងទៀត ឬមិត្តភ័ក្តិរបស់ខ្ញុំអំពីកូនរបស់ខ្ញុំ ឬប្តីខ្ញុំផ្ទាល់?**

កម្មវិធី WIC ការពារសិទ្ធិឯកជនរបស់អ្នក។ WIC នឹងមិនចែករំលែកព័ត៌មានណាមួយដោយគ្មានការអនុញ្ញាតរបស់អ្នកទេ។ នេះរួមបញ្ចូលទាំងពេលវេលាណាត់ជួប និងព័ត៌មានវេជ្ជសាស្ត្រ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើសមាជិកបុគ្គលិក WIC ជឿជាក់ថា កុមារម្នាក់កំពុងមានគ្រោះថ្នាក់ បុគ្គលិកនោះត្រូវបានតម្រូវឲ្យរាយការណ៍ពីករណីនេះទៅកាន់សមាជិកបុគ្គលិក DHHS ដែលនឹងតាមដានជាមួយគ្រួសាររបស់កុមារនោះ។

**ចុះប្រសិនបើខ្ញុំបាត់សែក WIC របស់ខ្ញុំ ឬសែកទាំងនោះបានជ្រុះបាត់ ត្រូវចោរលួច ឬខូច?**

ជូនដំណឹងដល់ការិយាល័យ WIC របស់អ្នកភ្លាមៗ។ សូមចាត់ទុកសែក WIC របស់យើងដូចជាសាច់ប្រាក់។ ទុកសែកទាំងនោះនៅកន្លែងដែលមានសុវត្ថិភាព។

**តើខ្ញុំត្រូវទិញអ្វីៗទាំងអស់ដែលមាននៅលើសែក WIC របស់ខ្ញុំឬ?**

ទេ អ្នកមិនត្រូវបានតម្រូវឱ្យទិញអ្វីៗទាំងអស់ដែលមាននៅលើសែក WIC របស់អ្នកទេ។ អ្នកអាចទិញតែអាហារដែលអ្នកដឹងថាអ្នកនឹងប្រើ។

**ចុះបើខ្ញុំបានចាយសែក WIC របស់ខ្ញុំទាំងអស់ ហើយខ្ញុំអស់ម្សៅទឹកដោះគោសម្រាប់កូនរបស់ខ្ញុំ?**

WIC អាចត្រឹមតែផ្តល់ម្សៅទឹកគោះចំនួនជាក់លាក់មួយជូននៅខែនីមួយៗ។ នៅពេលកូនរបស់អ្នកកាន់តែធំ វាអាចត្រូវការម្សៅទឹកដោះគោកាន់តែច្រើនជាងចំនួនម្សៅទឹកដោះគោដែលអ្នកទទួលបានពី WIC ។ ប្រសិនបើករណីនេះកើតឡើង អ្នកនឹងត្រូវទិញម្សៅទឹកដោះគោបន្ថែម រហូតដល់ពេលចាប់ផ្តើមទទួលសែក WIC បន្ទាប់របស់អ្នក។